# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៧ ខែ តុលា ឆ្នាំ២០២០

# អូស្ត្រាលីចាប់ដៃគ្នាជាមួយគណៈកម្មការមូលប័ត្រកម្ពុជា ក្នុងការកៀងគរទុនសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ

ថ្ងៃនេះ រដ្ឋាភិបាលអូស្ត្រាលី និងគណៈកម្មការមូលប័ត្រកម្ពុជា (គ.ម.ក) រួមគ្នាបានបើកឱ្យដំណើរការ គម្រោងកៀងគរទុនសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ក្នុងទីផ្សារមូលប័ត្រ ក្រោមអធិបតីភាព ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងឯកឧត្តម ស៊ូ សុជាតិ អគ្គនាយកនៃគណៈកម្មការមូលប័ត្រកម្ពុជា។

ទីផ្សារមូលធនក្នុងស្រុក ប្រកបដោយប្រសិទ្ធភាព នឹងជួយឱ្យកម្ពុជា អាចធ្វើពិពិធកម្ម ប្រភពមូលធនសំរាប់វិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនបាន ហើយក៏សម្រួលឱ្យកម្ពុជា មានលទ្ធភាពបត់បែនបានងាយស្រួល ក្នុងការឆ្លើយតបនឹងកិច្ចប្រឹងប្រែង ក្នុងការស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ពីការប៉ះពាល់ពីជំងឺកូវីដ-១៩។

ឯកឧត្តមឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា «យើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ.ម.ក និងភាគីពាក់ព័ន្ធទាំងឡាយ ដើម្បីសម្រួលដល់ការបង្កើតលក្ខខណ្ឌ សម្រាប់ទីផ្សារមូលធនរយៈពេលវែងមួយ ប្រកបដោយភាពរស់រវើក ដែលគាំទ្រដល់កាអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ របស់កម្ពុជា»។

តាមរយៈ កញ្ចប់ថវិកា ៥០លានដុល្លាអូស្ត្រាលី ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងកម្ពុជា កម្មវិធីវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធ (3i) រដ្ឋាភិបាលអូស្ត្រាលីធ្វើការជាដៃគូជាមួយគណៈកម្មការមូលប័ត្រកម្ពុជា ពង្រឹងការកៀងគរមូលធនក្នុងស្រុក សម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ។ រួមមានការផ្តល់ជំនួយបច្ចេកទេស ដើម្បីអភិវឌ្ឍក្របខ័ណ្ឌច្បាប់ សម្រាប់បំណុលរយៈពេលវែង ពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ និងបង្កើតវិធានការណ៍នានា ដើម្បីបង្កើតយន្តការបន្ថែម សំរាប់វិស័យឯកជនវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធ ។ ជំនួយបច្ចេកទេសនេះ នឹងបង្កើតគម្រោងហេដ្ឋារចនាសម្ព័ន្ធមួយ ឱ្យដំណើរការ ផងដែរ។

ឯកឧត្តមឯកអគ្គរាជទូត Kang បានមានប្រសាសន៍បន្ថែមថា «អូស្ត្រាលីប្តេជ្ញាជួយកម្ពុជាក្នុងដំណើរពិពិធកម្មប្រភពមូលធនក្នុងស្រុក សម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ព្រោះយើងជឿជាក់ថា ដំណើរពិពិធកម្មនេះ មានសារៈសំខាន់ ក្នុងដំណើរអភិវឌ្ឍន៍សេដ្ឋកិច្ចមួយដែលធន់ និងគិតគូរដល់ផលប្រយោជន៍ប្រជាជនគ្រប់ៗគ្នា។ វាពិតជាមានសារៈសំខាន់ជាពិសេស ក្នុងពេលដែលកម្ពុជាកំពុងស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ពីផលប៉ះពាល់របស់ជំងឺកូវីដ-១៩»។

ឯកឧត្តមឯកអគ្គរាជទូត Kang បានមានប្រសាសន៍ទៀតថា «ខ្ញុំទន្ទឹងរង់ចាំមើល សក្តានុពលនៃទីផ្សារមូលធនក្នុងស្រុករបស់កម្ពុជា ចេញផ្លែផ្កា»។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

